**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលនៃទស្សនកិច្ចការងាររបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅសាធារណរដ្ឋបារាំង

1. នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២ សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបំពេញទស្សនកិច្ចការងារនៅសាធារណរដ្ឋបារាំង មុនពេលអញ្ជើញចូលរួមកិច្ចប្រជុំកំពូលរំលឹកខួបលើកទី៤៥ នៃទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-សហភាពអឺរ៉ុបនៅទីក្រុងព្រុចសែល។ អញ្ជើញអមដំណើរសម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងឱកាសនោះ រួមមាន ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ, ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា, ឯកឧត្តម សុខ ចិន្តា សោភា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងមន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលផ្សេងទៀតផងដែរ ។

2. នៅក្នុងទស្សនកិច្ចនេះ សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវបាន ឯកឧត្តម អេម៉ានូអែល ម៉ាក្រុង ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង អញ្ជើញចូលរួមក្នុងសន្និសីទអន្តរជាតិ «សាមគ្គីភាពជាមួយប្រជាជនអ៊ុយក្រែន» នៅសាលសន្និសីទរបស់ក្រសួងការបរទេសបារាំង នៅទីក្រុងប៉ារីស និងទទួលស្វាគមន៍យ៉ាងកក់ក្តៅព្រមទាំងរៀបចំអាហារការងារពេលល្ងាចជូនជាកិត្តិយសដ៏ខ្ពង់ខ្ពស់នៅវិមានអេលីហ្សេ (Élysée Palace) ។ សម្តេចតេជោ បានចូលរួមផងដែរក្នុងកិច្ចប្រជុំរៀបចំឡើងដោយសហព័ន្ធនិយោជកបារាំងអន្តរជាតិ (MEDEF International) និង ជួបជាមួយនឹងតំណាងក្រុមហ៊ុន Vinci Airports ។

3. នៅក្នុងសន្និសីទអន្តរជាតិ «សាមគ្គីភាពជាមួយប្រជាជនអ៊ុយក្រែន» សម្តេចតេជោនាយករដ្ឋមន្ត្រី បានធ្វើបទអន្តរាគមន៍ដោយរំលេចពីដំណើរកម្ពុជា, ធ្លាប់ជាប្រទេសដែលរងគ្រោះទុក្ខសោកហែកហួរ និងបំផ្លិចបំផ្លាញខ្ទេចខ្ទាំដោយសារសង្គ្រាមរ៉ាំរ៉ៃ, បានក្លាយជាប្រទេសដែលមានសន្តិភាព និងសេរីភាព មានកំណើនសេដ្ឋកិច្ចខ្ពស់ និងបានក្លាយជាសមាជិកដ៏សកម្មមួយនៃសហគមន៍អាស៊ាន ដែលបានចូលរួមប្រកបដោយជវភាពក្នុងកិច្ចការតំបន់និងអន្តរជាតិ។ កម្ពុជាយល់ច្បាស់ណាស់និងឱ្យតម្លៃខ្ពស់បំផុតដល់សន្តិភាពនិងស្ថិរភាពក្នុងស្រុករបស់ខ្លួន ហើយក៏ប្រឹងប្រែងខ្ពស់ដើម្បីជួយប្រទេសផ្សេងទៀតនៅលើសកលលោក ដែលរងផលប៉ះពាល់ដោយសារសង្គ្រាម។ កម្ពុជានឹងផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងបទពិសោធន៍ដោយផ្ទាល់



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

ដល់អ្នកជំនាញដោះមីន និងថ្នាក់ដឹកនាំនៃអង្គភាពផ្តល់សេវាកម្មរដ្ឋក្នុងគ្រាអាសន្ននៃប្រទេសអ៊ុយក្រែន ចំនួន១៥នាក់ នៅក្នុងប្រទេសកម្ពុជា នៅខែមករា ឆ្នាំ២០២៣ ខាងមុខនេះ ។

4. **សម្តេចតេជោ** ក៏បានគូសបញ្ជាក់ពីការគោរពគោលការណ៍ទាំងឡាយនៃទំនាក់ទំនងអន្តរជាតិ ដែលផ្អែកលើច្បាប់និងការគោរពអធិបតេយ្យ និងការគោរពបូរណភាពទឹកដីនៃរដ្ឋឯករាជ្យ ព្រមទាំងបានសម្តែងនូវសាមគ្គីភាព និងនៅឈរជាមួយប្រជាជនអ៊ុយក្រែនក្នុងគ្រាដ៏លំបាកនៃសង្គ្រាម ដែលពោរពេញដោយវិនាសកម្មនេះ ។

5. នៅវិមានអេលីហ្សេ (Élysée Palace) បន្ទាប់ពីការទទួលការស្វាគមន៍ប្រកបដោយកិត្តិយស និង យ៉ាងកក់ក្តៅបំផុត ពីសំណាក់ **ឯកឧត្តម អេម៉ានូអែល ម៉ាក្រុង** ប្រធានាធិបតីបារាំង **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានធ្វើសន្និសីទកាសែតរួមជាមួយនឹងឯកឧត្តមប្រធានាធិបតីបារាំង បន្ទាប់មកបានធ្វើការផ្លាស់ប្តូរ ពិភាក្សាគ្នាប្រកបដោយភាពស្និទ្ធស្នាល ស្មោះត្រង់ និងជឿទុកចិត្តគ្នា លើប្រធានបទសំខាន់ៗជាច្រើននៃការពង្រឹងពង្រីកចំណងមិត្តភាព និងប្រវត្តិសាស្រ្ត ព្រមទាំងកិច្ចសហប្រតិបត្តិការរវាងកម្ពុជានិងបារាំង។

6. **សម្តេចតេជោនាយករដ្ឋមន្ត្រី** និង **ឯកឧត្តមប្រធានាធិបតីបារាំង** បានអបអរសាទរ និងពេញចិត្តចំពោះវឌ្ឍនភាពនៃទំនាក់ទំនងមិត្តភាព និងប្រវត្តិសាស្រ្តដ៏យូរលង់ និងកិច្ចសហប្រតិបត្តិការពហុវិស័យរវាងប្រទេសយើងទាំងពីរ ជាពិសេស នៅក្នុងវិស័យសេដ្ឋកិច្ច ធុរកិច្ច អប់រំ ទឹកស្អាត ធារាសាស្រ្ត ហេដ្ឋារចនាសម្ព័ន្ធ បរិស្ថាន ការប្រែប្រួលអាកាសធាតុ ថាមពលកកើតថ្មី (កើតចេញពីពន្លឺព្រះអាទិត្យ) កសិកម្ម កសិ-ឧស្សាហកម្ម វប្បធម៌ បេតិកភណ្ឌ ទេសចរណ៍ ... ។ល។

7. ថ្នាក់ដឹកនាំទាំងពីរ បានអបអរសាទរខួបទី៣០នៃការបញ្ចូលរមណីដ្ឋានអង្គរប្រវត្តិសាស្រ្តអង្គរ នៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូ នៅខែធ្នូ ឆ្នាំ២០២២នេះ ព្រមទាំងអបអរសាទរការប្រារព្ធខួបទី៣០របស់គណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្រ្តអង្គរ (ICC-Angkor) និងខួប៧០ឆ្នាំនៃឯករាជ្យភាពរបស់កម្ពុជា នៅឆ្នាំ២០២៣ ខាងមុខ ។

8. ថ្នាក់ដឹកនាំទាំងពីរ ក៏បានផ្លាស់ប្តូរយោបល់ផងដែរ ក្នុងនាមជាដៃគូសន្ទនាប្រកបដោយការជឿទុកចិត្តគ្នាស្តីពីប្រធានបទតំបន់និងពិភពលោក រួមមាន ប្រធានប្តូរវេនអាស៊ានរបស់កម្ពុជា យុទ្ធសាស្រ្តឥណ្ឌូ-ប៉ាស៊ីហ្វិក ករណីវិបត្តិនៅប្រទេសមីយ៉ាន់ម៉ា សង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ... ។ល។ ថ្នាក់ដឹកនាំទាំងពីរ បានឯកភាពក្នុងការធ្វើការអំពាវនាវឱ្យបញ្ឈប់ជាបន្ទាន់ នូវការវាយប្រហារតាមអាកាស និងការវាយប្រហារដោយយន្តហោះគ្មានមនុស្សបើក(ដ្រូន) ប្រឆាំងនឹងប្រជាជន និងហេដ្ឋារចនាសម្ព័ន្ធស៊ីវិលអ៊ុយក្រែន។

9. នៅចុងបញ្ចប់ **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** បានថ្លែងអំណរគុណដល់ **ឯកឧត្តមប្រធានាធិបតី អេម៉ានុយអែល ម៉ាក្រុង** ចំពោះបដិសណ្ឋារកិច្ចដ៏កក់ក្តៅ និងការផ្តល់នូវការស្រឡាញ់រាប់អានយ៉ាងជ្រាលជ្រៅ និងរាក់ទាក់បំផុត ។

10. នៅក្នុងកិច្ចប្រជុំរៀបចំឡើងដោយសហព័ន្ធនិយោជកបារាំងអន្តរជាតិ (MEDEF International) បន្ទាប់ពីបានស្វាគមន៍យ៉ាងកក់ក្ដៅ ដោយលោក **ហ្វ្រង់ស្វ័រ ខរប៉ាំង** (Francois Corbin) ប្រធានក្រុមប្រឹក្សាសហគ្រាសកម្ពុជា-បារាំង និងជាតំណាងពិសេសរបស់ក្រសួងការបរទេសបារាំង សម្រាប់ទំនាក់ទំនងសេដ្ឋកិច្ចជាមួយប្រទេសអាស៊ាន ដែលបានវាយតម្លៃខ្ពស់ចំពោះកាលានុវត្តភាព និងភាពអំណោយផលនៃបរិយាកាសធុរកិច្ច និងវិនិយោគរបស់កម្ពុជា **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានធ្វើបទអន្តរាគមន៍បង្ហាញដល់ធុរជន និងវិនិយោគិន ប្រធាននិងជាតំណាងក្រុមហ៊ុនបារាំង អំពីលទ្ធភាពដែលកម្ពុជាអាចងើបចេញពីវិបត្តិ Covid-19 ទាំងនេះបានយ៉ាងឆាប់រហ័ស ដោយរក្សាបាននូវភាពធន់នៃសេដ្ឋកិច្ច និងដែលបានអនុញ្ញាតឱ្យកម្ពុជានៅតែអាចឈរជើងជាគោលដៅវិនិយោគដ៏មានសក្តានុពលមួយនៅក្នុងតំបន់។ **សម្តេចតេជោ** ក៏បានបញ្ជាក់ផងដែរអំពីសក្តានុពលវិនិយោគ និងឧត្តមភាពសំខាន់ៗរបស់កម្ពុជា និងបានអំពាវនាវឱ្យក្រុមហ៊ុនបារាំងអញ្ជើញមកធ្វើការសិក្សាស្វែងយល់ និងបណ្តាក់ទុនវិនិយោគនៅកម្ពុជា ដើម្បីទាញយកប្រយោជន៍ជាអតិបរមាពីកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីនានា ជាពិសេសក្នុងវិស័យកែច្នៃចំណីអាហារ វិស័យវេជ្ជសាស្ត្រនិងឱសថ វិស័យកម្មន្តសាលធុនស្រាល និងវិស័យយានយន្តជាដើម។ **សម្តេចតេជោ** បានធានាជូនវិនិយោគិនគ្រប់រូបនូវបរិស្ថានវិនិយោគប្រកបដោយភាពអំណោយផល ជាពិសេស សន្តិភាព សន្តិសុខ និងស្ថិរភាពនយោបាយ ក៏ដូចជាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌច្បាប់ ដែលប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងភាពអាចប៉ាន់ប្រមាណបាន។

11. នៅក្នុងជំនួបដាច់ដោយឡែកមួយទៀត **សម្តេចតេជោនាយករដ្ឋមន្ត្រី** និង **លោក Nicolas Notebeart** អគ្គនាយក ក្រុមហ៊ុន Vinci Airports របស់បារាំង បានពិភាក្សាគ្នាអំពីវឌ្ឍនភាពនៃភាពជាដៃគូវិនិយោគរបស់ក្រុមហ៊ុន Vinci និងរាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍនិងប្រតិបត្តិការអាកាសយានដ្ឋានអន្តរជាតិទាំងបីនៅកម្ពុជា។ **សម្តេចតេជោ** បានអបអរសាទរ ក្រុមហ៊ុន Vinci Airports ដែលនាពេលបច្ចុប្បន្ននេះ ទទួលបានកិច្ចសន្យាសម្បទានគ្រប់គ្រងព្រលានយន្តហោះជាង៥០ នៅក្នុងទ្វីបអាស៊ី អឺរ៉ុប និង អាមេរិក ដោយសារបានប្រើប្រាស់គម្រូកិច្ចសន្យាសម្បទាននៅកម្ពុជាដែលកិច្ចសន្យាដំបូងគេបង្អស់ និងគម្រោងពង្រីកទ្រង់ទ្រាយធំព្រលានយន្តហោះអន្តរជាតិ ខេត្តព្រះសីហនុ ដែលនឹងចាប់ផ្តើមនៅដើមឆ្នាំ២០២៣ខាងមុខ។ លោក **Nicolas Notebeart** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ **សម្តេចតេជោ**ដែលតែងតែផ្តល់សេចក្តីទុកចិត្តដល់ក្រុមហ៊ុន Vinci ចំពោះភាពជាដៃគូឈ្នះឈ្នះជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាចាប់តាំង ពីទសវត្សរ៍ឆ្នាំ១៩៩០រហូតមកទល់នឹងពេលបច្ចុប្បន្ន ៕

ថ្ងៃព្រហស្បតិ៍ ៧រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២